# នេះច្បាប់សត្រាជុច

## នេះបទបន្ទោលកាក

ដំណើរដំណាល ដំណើរពីកាលព្រេងនាយ មានជានិយាយ ពីត្រីនិងជុចនោះណា។
គួរឱ្យចូលពេក ជុចចេះដដែកចរចា តែត្រីមិនថា នោះបទវាមានរូបកាយ។
ឯជុចនោះតើ មនុស្សផងគេធ្វើនាយអាយ ផ្តៅវល្លិ៍ច្នាក់ច្នាយ ប្រទាក់ប្រទើសទេតើ។
មិនគួរនឹងមាន រូបរសវិញ្ញាណប្រសើរ ចេះដឹងដំណើរ ដំនៀលទំនៀមត្រីវិញ។
ពាក្យពីបុរាណ នោះលោកនិទានមែនមិញ សម្តែងចែងចេញ អំពីព្រះព្រហ្មលោកា។
កាលករផែនដី កើតមនុស្សប្រុសស្រីផងណា បក្សីបក្សា ក៏សឹងតែចេះស្រដី។
ហេតុដោយអំណាច ព្រះព្រហ្មឯងអាចជប់ខ្មី សព្វសត្វអ្វី។ ឈើព្រៃសឹងចេះចរចារ។
ហេតុបទនោះហោង កុំឱ្យអ្នកផងសង្កា សន្និះក្នុងចិត្តចិន្តា មិនមានដូចពាក្យលោកថ្លែង។
ដំណើរៀងរាប លោកលើកជាកាព្យល្បើកល្បែង យូរមកអង្វែង ទើបតែងជាពាក្យវោហារ។
ពីព្រេងមកច្បាស់ មែនមានតាចាស់មួយណា កបនៅភរិយា តែងនឹងនេសាទត្រីផង។
ធ្វើអស់លបលាយ ចាក់ជុងសពសាយរាយមង ទាំងឈ្នាងអន្ទង ជញ្ជាត់ចិញ្ចឹមអាត្មា។
រូបអាក្រក់ក្រៃ ហាក់ពុំវិស័យមនុស្សា មើលមុខដូចស្វា ស្រមូវស្រមូមស្កូវស្កាញ។
ទោះហាស្រដី នឹងជីចំណីបូញបាញ ច្មេញសោតស្មេញស្វាញ ប្រជិបប្រជួសពីរបី។
សក់សោតក្រញាញ់ ក្រញេសរួញរេញសិរសី មុខមាត់ខ្ញូវខ្ញី សម្តីខ្លាំងខះសោះសារ។
សព្វថ្ងៃសង្វាត ស្វះស្វែងនេសាទមច្ឆា បានមកហើយណា រើសរកស្រាល់តែធាត់ធំ។
ធ្វើញាំភ្លាសា ទើបទៅទិញស្រាមកជុំ ផឹកស៊ីពិតពុំ មិនលោះដល់មួយវេលា។
មានទាំងសម្លួ សុទ្ធសឹងខ្លួខញាំភ្លា ស៊ីផឹកជុំគ្នា ស្រេចទៅរួសរកនេសាទ។
អ្នកខ្លះដាក់លប រកស៊ីរបបដោយខ្នាត ខ្លះសោតសង្វាត ដាក់លាយរាយមងទីទៃ។
ឯចាស់អប្បលក្ខណ៍ ស្វះស្វែងដើរដាក់ជុចនៃ គយគន់រំពៃ រំពឹងរកច្រកជ្រលង។
ដោយបឹងដោយវាល ត្រង់ណាមានជ្រាលត្រីពង គាត់ស្គាល់គន្លង កន្លែងត្រីតែងយាត្រា។
ឃើញស្រេចគាត់ស្រាស់ រាយជាសម្រាស់ហើយណា ដាក់ស្រេចផ្តាំថា វើយជុចឯងខំប្រឹងប្រាណ។
សម្ងំមើលត្រី ឃើញវាមកខ្មីចូលថ្កាន ឯងរួបឱ្យបាន កុំឱ្យបម្រាសរួចឡើយ។

ដាក់ស្រេចគយគន់ យល់ថ្ងៃទៀបទន់ទៅហើយ ពិតពុំលង់ឡើយ វិលទៅលំនៅអាត្មា។

ផ្លូតទឹកស៊ីបាយ សើចលេងក្អាកក្អាយចរចា ចំអន់ភរិយា យើងភ្លាស្អែកទៀតឱ្យបាន។

ចំណាំអញថា ស្អែបានត្រីប្រាមិនខាន ដុកសោតគង់បាន ត្រីផ្តោគ្រាន់ស្ងោរក្បាលវា។

ប្រពន្ធស្រដី បើឯងរកត្រីមកភ្លា អញឯងធានា និងរកបេះម្ជូរក្រូចឆ្មារ។

អំពិលសណ្តាន់ រឿយៗវាទ្រាន់ធុញទាល មិនដូចក្រូចឆ្មារ ជូរជ្រះស្រលះដើងធ្មេញ។

ប្តីនិងប្រពន្ធ ជំអកចំអន់លងលេង ឯជូនចាស់មិញ ក្រោកចេញទៅរៀបក្រយា។

បាយទឹកចំណី លើកមកឱ្យប្តីពិសា មានសព្វប្រការ ខ្ជូខសម្លសាអាំង។

ចំណីគ្រប់មុខ មានទាំងកំប៉ុកស្រាខ្លាំង ដាក់ថ្នាំសម្រាំង ចម្រើនកម្លាំងឱ្យប្តី។

ចាក់ជាត់ហុចហ៏ ប្តីទទួលអរដីកខ្មី ដៃលូកចាប់ត្រី អាំងសាបជ្រលក់ទឹកគ្រឿង។

ស៊ីហើយផឹកផង ស្រវឹងកន្ទួងងោកងឿង សស្រឹមសៀវស្រឿង ភ្នែកលឿងក្រហមមុខងាំង។

ប្រវារកភ្លា លូកដៃចាប់ពាត្រីអាំង ធ្វើមុខមឹងមាំង ទាររកត្រីអាំងងាន់ខ្លាញ់។

ហើយហុតសម្ល សម្លឹងរកខត្រីក្រាញ់ គង់តែមិនឆ្ងាញ់ ស្រលាញ់តែជ្រូកសណ្តែក។

លើកកនិងស៊ី មើលមុខមមីធ្មេចភ្នែក ពាក្យក្អេងជជែក ថាស្អែកមាសបងកុំភ័យ។

បងធានាប្រាណ រកត្រីឱ្យបានពីព្រៃ ឱ្យប្អូនមាសមៃ រកក្រូចនិងគ្រឿងទុកទៅ។

ថាហើយងោកងប់ ដល់ដួលជ្រុលជ្រប់លើភ្លៅ ប្រពន្ធគ្រាទៅ ដាក់ក្នុងដំណេកនិទ្រា។

អង្គុយងាកបក់ លុះប្តីដេកលក់យូរយារ ប្រាស់ប្រាណប្របគ្នា លង់លក់ស្រមុកទីទៃ។

រីដំណើរនេះ យើងនឹងទុកស្ទេសក្បិននៃ នឹងថ្លែងស្រដី ឯត្រីត្រេចត្រង់យាត្រា។

បរបទនិទាន កាលនោះមែនមានមច្ឆា ត្រីផ្តោមួយណា បណ្តើរនូវកូនច្រើនក្រៃ។

កូនតូចៗលន់ ទើបនឹងប្រប៉ុនមេដៃ ហិចហែលច្រៀវប្រៃ រកស៊ីដោយដងមាត់បឹង។

ប្រមាណមួយស្រែ ច្រើនក្រៃឥតឯថ្លែងថ្លឹង ហែលហក់សម្រឹង សម្រាកពួននឹងសម្រាម។

ខ្លះហែលមុនមេ ច្ងាយទៅលេលេប្លែមប្លម មេមុជទៅតាម ប្រកិតប្រកៀងនាំមក។

ជូនកាលភ្ញាក់ផ្អើល រសេចរសាចច្រៀវជ្រក ពឹងពួនក្រោមចក សំកាំងសំកុកចាំមេ។

រអើលខ្លួនឯង ភិតភ័យខ្លាចក្រែងរំពេរ រំពៃរារេ ឃើញមេមុជមកជុំគ្នា។

តែងនឹងប្រយ័ត្ន មិនឱ្យអស់សត្វពាន្ធា នាំកូនលេលា ហិចហែលរិះរកភោគ្គា។

ដោយដងមាត់បឹង ខៀវខ្វារទ្រហឹងត្រៀបត្រា សប្បាយចិន្តា ឥតឯនឹងមានសៅហ្មង។

ហេតុកម្មមច្ឆា នឹងឱ្យអាសារនេះម្ដង ទាំងអស់កូនផង ហិចហែលដោយដងផលសា។
ដំណើរដើនង ដំណើរត្រីផងយាត្រា ពើបនឹងដុចណា ត្រីស្រែកថារ៉ឺយចៀសចេញ។
ដុចថាយ៉ើត្រី ម្ដេចឯងស្រដីច្នោះមិញ ហៅហ៊ានបណ្ដេញ ឱ្យអញជៀសចេញពីផ្លូវ។
ឯងនេះហៅកាច ចិត្រចោរកំណាចពេកកូវ ខុសច្បាប់ពុំត្រូវ ឱ្យអញជៀសឯងវិញណា។
បើចិត្រឯងមាន មុះមកបំពានពុះពារ អញនេះមិនរា មិនរួញមិនរត់ខ្លាចឯង។
មិនដឹងដៃដុច ចំណាប់ចំណុចលើសលែង ឥតកោតឥតក្រែង រអែងមិនខ្លាចតតាំង។
ត្រីថាអិះអើ ប៉ើងរើងទេតើម្ដេចខ្លាំង អួតមានកម្លាំង មករាមករាំងនៅផ្លូវ។
តែខំអញស្ទុះ ទម្លាយទម្លុះឥឡូវ អញនេះមិនស្ងូវ កោតខ្លាចនរណាឡើយហោង។
ដុចថាបើច្នោះ អញ្ជើញមកចុះលងម្ដង ឱ្យយល់នេះបង រិទ្ធីតេជះតេជដៃ។
ត្រីស្ទុះភ្លាមចូល ក្នុងដុករមួលហើយនៃ ជំពាក់ក្រក្រៃ រើខ្លួនពុំរួចចេញឡើយ។
ដុចថាអើចៅ ម្ដេចម្ដងហាក់នៅកន្តើយ ស្ងៀមស្ងាត់ព្រងើយ បំណាច់អាងអួតចេស្ដា។
ថ្វីមិនទម្លុះ ទម្លាយទៅចុះត្រង់ណា ដាច់ដាចមិនថា សឹមតាគាត់ជួសជាថ្មី។
ត្រីព្រុដុចថា ខំស្ទុះបំពារទៅខ្មី រឹងអស់ឥន្ទ្រីយ មិនមានរបូតឡើយណា។
រឹតរួតមាំមួន ទើបត្រីភ្ញាក់ខ្លួនគិតថា ឱសឱអនិច្ចា អាត្មាអញខំក្បិនក្បៀយ។
ទើបត្រីអង្វរ ទៅដុចពាក្យល្អថាហៃ អ្នកដុចម្ចាស់ថ្លៃ អ្នកកើយអាណិតលែងខ្ញុំ។
រីពាក្យពីមុន ខ្ញុំថាជាស៊ុនពុំសម យល់ខុសខាងខ្ញុំ ពាក្យធំប្រាកដមែនហើយ។
ព្រោះខ្លួនល្ងង់ខ្លៅ មិនយល់រាក់ជ្រៅទេឡើយ ជួល្ងង់ឥតត្រើយ មកឆ្លើយប្រលងអាងអួត។
ខ្ញុំនេះចោតក្អាត់ ឧបមារដូចសត្វត្រកួត ម្ដេចឡើយហ៊ានអួត ប្រកួតប្រលងនឹងថ្កែ។
ប្រុងប្រាណចំអើត ចំកោងខ្នងខ្ញើតក្រអែ មិនដឹងអីថ្កែ សង្កត់កលេងខាំទៅ។
កលមួយដូចសត្វ កណ្ដូបតូចក្អាត់ខ្ជួលខ្មៅ ឃើញភ្លើងប្រាលឆ្អៅ ម្ដេចឡើយហើរទៅលុតភ្លើង។
ឈ្លួលឆេះអស់ស្លាប រលើងរលាត់ដៃជើង មិនដឹងអីភ្លើង ក៏ហ៊ានចចើងចូលទៅ។
ខ្លួនខ្ញុំនេះណា ហៅពេញជាមហាចោតខ្លៅ អាណិតខ្ញុំទៅ បើកលែងយកបុណ្យបរលោក។
ដុចថាបុណ្យៗ ឯងអួតពីមុនកកោក ឥឡូវម្ដេចមក បន្ទោកបន្ទយអាត្មា។
ពោលពាក្យឱ្យចាក បើកលែងឯងចេញមិនថា ចាំម្ចាស់អញណា គាត់យកទៅលែងក្នុងថ្នាំង។
ត្រីព្រុដូច្នោះ រឹងរឹតថែមថប់ស្លន់ស្លាំង ភិតភ័យភ័នភាំង អង្វរទៅដុចទៀតថា។

| | | | |
|---|---|---|---|
| អ្នកជុចអម្ចាស់ | កុំមានប្រសាសន៍ថ្មោះណា | ឱ្យអ្នកមេត្តា | កុំចាំម្ចាស់អ្នកគាត់មក។ |
| ជុចថាម្ចាស់អញ | ចិត្រគាត់ស្រលាញ់រិះរក | គ្រឿងគ្រៅគ្រប់មក | ម្ជូម្ជត់ទុកដាក់។ |
| ខ្លួនខ្ញុំនេះណា | បានឮគាត់ថាចង់គ្រាក់ | សាច់សោតប្រលាក់ | អំបិលធ្វើងៀតទុកទៅ។ |
| ឱ្យតែក្រៀមល្អ | គ្រាន់ស៊ីបបរក្តៅ។ | ស្រស់ស្រូបតទៅ | រិះរកនេសាទនាយអាយ។ |
| ម្ចាស់អញគាត់ថា | ក្បាលឆ្កោពិសាចូលបាយ | ស្ងោរជ្រក់ម្ជូរស្វាយ | ហើយដាក់ម្ទេសផ្សំផង។ |
| បើស៊ីឱ្យល្មម | អស់បាយមួយគោមជាម្តង | កូនមកស្ទាបខ្នង | មិនដឹងថាជារុយទុំ។ |
| ត្រីស្តាប់ពាក្យជុច | ថាឥតក៏កុចស្ទើរយំ | ដកដង្ហើមធំ | ខះខំថ្លាស់ឆ្លើយទៅថា។ |
| អ្នកជុចម្ចាស់ថ្លៃ | សាច់ខ្ញុំនេះនៃពិសា | ពិតហើយគេថា | ស៊ីកូវមិនសូវឆ្ងាញ់ទេ។ |
| បើឆ្ងាញ់បាយ | ដាច់នៅជើងក្រាយជាងគេ | ឯទៀតគ្មានទេ | នឹងយកមកផ្ទឹមពុំបាន។ |
| ឯខ្ញុំជាឆ្កោ | ទោះអាំងទោះស្ងោរមែនមាន | ដោយសារវាឃ្លាន | ចីហើយក៏ពិសា។ |
| មិនថ្មោះទេ | បើនឹងត្អេរដោយថា | ពងពាក់សង្វារ | នោះយល់ឆ្ងាញ់ជាជាងជ្រក់។ |
| ប៉ុន្តែគឺមោះ | ដាក់នៅក្នុងពោះកូរគ្រូក | រត់ចាប់ដៃលូក | ដកក្បិនប្រញាប់ទើបបាន។ |
| បើខំអង្គុយ | បង្អង់សមរុយរោមប្រាណ | ហៀរហូរមិនខាន | ម្រមាណលើសពងកន្ទួរ។ |
| ហេតុនេះខ្ញុំថា | សាច់ពុំពិសាកុំយ | ពងសោតនាំវ | ហៀរហូរពុំជាឡើយនៃ។ |
| បើចង់ពិសា | សាច់ត្រីឯទៀតឆ្ងាញ់ក្រៃ | អ្នកកុំសង្ស័យ | សាច់ខ្ញុំនេះសាបទេនៃ។ |
| ជុចថាហៀរហូរ | មិនចេះស្ទុះចូលរកព្រៃ | ត្រង់នោះកុំភ័យ | តែឫស្លឹកគ្រៃជីកបាត់។ |
| បើវាហៀរខ្លាំង | ទៅយក(ឫស) រាំងមកកាត់ | ជាពកំណាត់ | ស្ងោរជីកទៅបាត់ជាម្តង។ |
| ឥឡូវសម្រេច | រកស៊ីតែសាច់ទេហោង | ពុំបានស៊ីពង | តែសាច់ទេហោងកុំភ័យ។ |
| ទើបត្រីឆ្លើយថា | បើចង់ពិសាមែននៃ | យល់ពុំប្រពៃ | សាច់ខ្ញុំនេះសាបសោះទេ។ |
| ឆ្ងាញ់អ្វីត្រង់ណា | ខ្ញុំមិនមុសាវៀចវេរ | ត្រង់នេះតាមតែ | អ្នកនឹងមេត្តាយកបុណ្យ។ |
| ជុចអើយបុណ្យ… | នោះហុចមកជាម្តង | នឹងវែកពុនផង | ទុកដាក់តម្កល់តម្កើង។ |
| ត្រីថាបើថ្មោះ | អ្នកហាមាត់ខ្ពស់ៗឡើង | ខ្ញុំក្រាបបាតជើង | សំពះសូមចុះចាញ់។ |
| ជុចថាមិនចោត | ឯងកុំបំភូតលើអញ | ឯងនឹងស្ទុះចេញ | បានអីជាម្ហូបស៊ីបាយ។ |
| ត្រីឮជុចថា | មិនមានមេត្តាបើកស្រាយ | សង្វេករូបកាយ | ម្លេះហើយសមស្លាប់អាសារ។ |
| បើតែត្រឹមខ្លួន | កម្មមក(ជួប) ជួនហើយណា | ស្លាប់រស់មិនថា | តាមវេរាព្រេងនាយ។ |

មកគិតនៃកូន សមរត់ប្រញូនព្រាត់ព្រាយ បែកខ្ញែកចេញឆ្ងាយ ហិចហែលរកម្ដាយពុំយល់។
ម្លេះសមអស់សត្វ ហិចហើរច្រវាត់រកកល់ ចាបចកអស់កល់ មិនសល់រួចរស់មួយឡើយ។
ត្រីភិតភ័យណាស់ អង្វរថាម្ចាស់ខ្ញុំមើយ កុំចង់ខ្ញុំឡើយ អ្នកស្រាយយកមគ្គផល។
សូមអ្នកប្រោសប្រាណ លែងខ្ញុំចេញបានកុសល ឱ្យខ្ញុំបានដល់ យល់កូនសំឡាញ់ខ្ញុំណា។
ដុចថាហង់ខ្វូច បើឯងចង់រួចអាត្មា ឯងកុំចរចា ស្រដីអង្វរអញថ្វី។
ឯងថាមគ្គផល អញគិតទៅយល់មែននៃ បើចង់រួចក្រៃ អង្វរតែថ្នាំងសម្ល។
ថាបើគេព្រម ស្រាកស្រួលល្ហាក់ស្មមអញអរ គេយកអង្វរ អញក៏បណ្ដោយតាមថ្នាំង។
ថប់តែគេខឹង ក្រញើតក្រញឹងឃាត់ឃាំង ចិត្រគេសោតខ្លាំង ទទឹងទទាំងទាស់ទែង។
បើថ្នាំងព្រមមិញ គិតតែម្ចាស់អញគេនឹងមិនលែង ពុគាត់ថ្វាថ្លែង ថាសាច់ខ្លួនឯងស្រស់ល្អ។
ខ្លាញ់ដូចស្នូលនំ កាត់ជាដុំៗហើយខ ទុកស៊ីនោះក៏ មួយខែមិនមានផ្អូមផ្អុស។
ខុសតែស្លអាំង សាច់ស្វិតក្រទាំងសាបសុះ បានតែក្រៀមក្រោះ ធ្វើជាងៀតជង់ងាយក្រៃ។
ត្រីពុដុចថា ដឹងខ្លួនជាក់ជានឹងក្ស័យ មិនមានអាល័យ ស្ដាយជន្មជីវិតអាត្មា។
គិតតែទៅកូន ពន្លកខ្លឹមខ្លួនសង្ឃារ ត្រីខំឆ្លើយថា ដុចកើយសមអ្នកប្រណី។
បើអ្នកនឹងចាប់ ចិត្តចង់សម្លាប់ខ្ញុំក្ដី ខ្ញុំពុំថាអី ប្រណីតែកូនកំព្រា។
បើឥតពីម្ដាយ សមនឹងខ្ចាត់ខ្ចាយមរណា ទើបដុចឆ្លើយថា វាពុំកំព្រាឡើយហោង។
ថប់អីកូននាង សមគេយកឈ្នាងទៅដង ឱ្យអស់ម៉ត់ហ្មង មូលប្អូនមូលបង...។
.................. ................................ ...................... .......................
អាដុចចិត្តហេរហារ មិនមេត្តាដល់តិចឡើយ វាស្ងៀមធ្វើព្រងើយ ឱ្យតែម្ចាស់វាមកចាប់។
ហើយវាថាសាច់ម្ដាយ ស៊ីនឹងបាយច្ញាញ់ចំណាប់ សមម្ទេះវាសម្លាប់ ឱ្យម្ដាយស្លាប់និងបង្ខំ។
ដូច្នេះឱ្យកូនស្ងួន លបលាក់ខ្លួនពួនសម្ងំ ក្នុងត្រើបទ្រាលឱ្យដុំ ទម្រាំធំសឹមកូនមាស។
អ្នកបែកចេញពីគ្នា រកអាហារស៊ីផ្ដេសផ្ដាស ល្ងាចកុំកូនទើសទាស់ វិលមកជួបជុំគ្នាវិញ។
ដេកយប់កុំដេកដុំ ខ្លាចត្រីធំត្របាក់ដេញ អ្នកដេកបែកគ្នាចេញ ឱ្យស្រលាស់នឹងងាយគេច។
ត្រីផ្ដាំកូនកាលនោះ លោផ្លាពោះទៅវំពេច ហាមាត់ហបៗដាច់ ខ្យល់ស្លាប់ទៅកាលនោះណា។
ឯអស់កូនត្រីនោះ ហែលផ្ដេកផ្ដោះមកតៀបត្រា ឃើញមេដាប់ដុចណា ស្លាប់អសារក្នុងដុចនៃ។
សម្បុរស្លេកស្លាំងសោត សឹងយំសោកមេទីទៃ ភ្នែកស្លឹងប្រឹងវំពៃ វំពឹងដុចនោះណា។

ខ្លះផ្អើលមើលជុចដាក់ ភិតភ័យភ្ញាក់រត់ច្រេចឆ្ញា ខ្សៀវខ្វាខ្វាចសោះសារ ហែលហក់រត់ទៅទីទៃ។

នេះបទភុជង្គ

នឹងថ្លែងសម្ដែងស្រដី ឯម្ចាស់ជុចនៃ លុះព្រឹកឡើងហើយ។
ភ្ញាក់ពីដំណេកជាត្រើយ ពិតពុំលង់ឡើយ លុបមុខស៊ីស្លា។
ក្រោកក្លាមក្រហែមហើយថា យើងព្រឹកនេះណា មានលាភកន្លង។
បើតាមដោយយាមអញហោង ថាដាំងសព្វដង ប្រទះសើមឆ្នាំង។
បានស្លបានខស្ងោអាំង ប្រាកដហ៊ានតាំង ឆ្នាំងយើងមិនស្ងួត។
ជូនចាស់ខឹងណាស់នឹងអួត ថាចាស់ចំកួត កុំអួតវាថ្លង់
ពីដើមគយើមកាន់ជុង ដឹងជាវាលង់ ប្រែប្រុងឯជុច។
ជៀលម្ល៉េះមិនចេះកកុច មិនថយមិនទុច មិនថប់នឹងក្រ។
មិនគិតកាន់របរ អួតតែអាងស្ល វាអរណាស់ណា។
ចាស់ប្ដីស្រដីទៅថា សព្វថ្ងៃនេះណា មិនឃើញលែងស៊ី។
កុំស្ដីមេខើយមុនី មានមាត់ចាំស៊ី កុំថាច្នេះច្នោះ។
ថាក្លាមស្លាយយាមចរចុះ ហើយដើរទៅស្មោះ ដល់កំពង់ទូក។
ដាក់សព្វចង្រប់ស្នរច្បូក ហើយអុំទូកក្រោក ដោយដងមាត់បឹង។
កាន់ច្បូកភ្នែកឈ្ងោកសម្លឹង ឃើញត្រីសម្រឹង ប្រាណប្រែប្រឹងចាក់។
វាងោកឯទូកញ័រញ្ញាក់ ភ្លាត់ជើងលោតធ្លាក់ ទៅក្នុងទឹកប្រាង។
ងើបឡើងគគុកដើមទ្រូង ខំហែលប្រគោង លើងលើទូកខ្មី។
តាចាស់ខឹងណាស់ស្រដី បន្ទោសទៅស្រី ប្រពន្ធឯផ្ទះ។
ព្រោះតែខ្មោចមេម្នោម្នះ វាស្ដីជៀលត្មះ ថាឯងច្នេះច្នោះ។
ទាស់ថ្ងែងហាងឯងស៊ីចុះ មិនតែបន្ទោស ធ្លាក់ទាំងទឹកផង។
ចាស់ខឹងក្រញ៉ឹងកន្លង ហើយអុំទូកទៅហោង ដល់ជុចនោះណា។
ក្រឡេកឃើញត្រីវាថ្លា លាន់មាត់ហើយថា ឱ៎ះឱលាភហើយ។

| | | |
|---|---|---|
| អញ្ចទឹកពីព្រឹកមិនស្បើយ | ឥឡូវមែនហើយ | មុខជាបានស្ងោរ។ |
| ពើបពះប្រទះនឹងថ្គោ | ត្រីនេះធំប៉ោង | វាខ្លាញ់តិចអី ។ |
| តាចាស់អរណាស់ឃ្នាតខ្មី | លូកដៃដោះត្រី | ពីជុចនោះមក។ |
| ដាក់ទុកស្រេចទើបយក | ជុចនោះទៅស៊ក | ដាក់ដូចដើមវិញ។ |
| ស្រេចហើយទើបថយទូកចេញ | អុំទូកវិលវិញ | ចូលចតទុកនៅ។ |
| ពុនត្រីឃ្នាតខ្មីដើរទៅ | ដល់ផ្ទះស្រែកហៅ | ប្រពន្ធទទួល។ |
| យាយចាស់អរណាស់ស្រាកស្រួល | ស្ទុះស្ទើរនឹងដួល | ទទួលត្រីទុក។ |
| ឃើញប្ដីបានត្រីរីកមុខ | រៀបស្លគិតទុក | ក្រែខ្វះឯម្ជូរ។ |
| ប្រើប្ដីថារ៉ឺយកុំយូរ | ឯងនៅគិតគូរ | បេះស្លឹកសណ្ដាន់។ |
| ប្ដីប្រឹងដើរទៅរន្ទាន់ | ដល់ដើមសណ្ដាន់ | ស្ទុះឡើងរំពេច។ |
| លូកដៃរំពៃនឹងក្ដិច | ស្រាំងផ្អើលហើរទិច | វាទិចសាយសុះ។ |
| ទិចភ្នែកត្រចៀកប្រមុះ | លាន់មាត់ថាឱស | អួយយាសអួយយួយ។ |
| យាយយើយស្លាប់ហើយមកជួយ | ម៉ែរើយឱអើយ | កុំឱ្យទិចពេក។ |
| ខំកាច់បានស្រេចមួយមែក | ស្ទើរនឹងយំស្រែក | ស្ទុះចុះម្នីម្នា។ |
| រត់ចេញឃ្នាតខ្នាញ់ប្រាប់ | ក្នាដល់នាងភរិយា | សួរទៅថាគេ។ |
| បេះបានសណ្ដាន់មិនទេ | ប្ដីថាមេៗ | បេះម្ដេចនឹងបាន។ |
| ស្រាំងលិចវាទិចសុះប្រាណ | ប្រឹងខំកាច់បាន | ប្រមាណស្លម្ដង។ |
| ប្រពន្ធថាគ្រាន់ហើយហោង | យកមកបត់ទង | បុកបង់សម្ល។ |
| បង់អស់ស្លឹកគ្រឿងបន្ត | ម្ទេសហើរល្អ | រំម្ងាប់ចម្អាប។ |
| បង់គ្រប់គ្រឿងសព្វដរាប | ជូនស្លឱ្យសាប | តម្រូវមាត់តា។ |
| មាត់គាត់ចូលចិត្ត | ផឹកស្រា ជូនចាស់ប្រវ៉ា | ម្នីម្នាជួសភ្លក់។ |
| ហុតវាជ្រុលទាល់ឈ្លក់ | រលាកគយក់ | ធ្វើមាត់បុញ្ចបាញ្ច។ |
| ជេរថាមេខូចមេលាញ | ធ្វើមាត់ស្ញេញស្ញាញ | កខិកកខុក។ |
| វាទៅស្រក់ទឹកភ្នែកតតក់ | ដោយសាវាឈ្លក់ | ហុតទឹកសម្ល។ |
| ជូនចាស់ថាអុញមើលនរ | ស្លាប់ទៅអញ់អរ | ចាស់អីចង្រៃ។ |

ឱ្យភ្លូកឱ្យដឹងសាបប្រៃ បានជាវាថ្វី ឱ្យទាល់តែឈ្លក់។
តាចាស់ឆ្លើយទៅនាងទុក អំបិលប្រហុក ល្មមស៊ីហើយណា។
ជូនចាស់ព្ទុហើយប្រវា ដោះដួសឱ្យតា សម្លទាំងគ្រោង។
ហុតគ្រួកដៃលូកសំកោង ពោះធំកំបោង កំពង់តែច្វាញ់។
ស៊ីអស់ទៅដួសទៀតមិញ ប្រពន្ធលលេញ សម្លក់ក្រលែត។
ជេរថាខ្មោចអាមនុស្សប្រេត ប្រឹងស៊ីទាល់ផ្អែត មិនគិតគេផង។
កូនចៅពីមុខពីខ្នង មនុស្សអីជួរផង មិនគិតក្រោយមុខ។
បំណាច់អញស្លអាញ់ស្លុក ប្រឹងស៊ីមិនទុក តិចទួចឱ្យគេ។
ប្ដីថាឈប់ៗណាមេ សម្លនៅទេ កន្លះទាំងថ្នាំង។
ដោយសារវាអស់កម្លាំង កុំស្រដីខ្លាំង វាខ្មាស់អ្នកផង។
ជូនចាស់ខឹងណាស់កន្លង ប្រែមុខប្រែខ្នង សម្លក់ឱ្យប្ដី។
ឱទរស្រដី ដោយសារចិត្តស្រី ខឹងក្ររសាយ។
ទាល់តែប្ដីស៊ីលែងបាយ ទើបទៅកកាយ ដួសមកជាក្រោយ។
ហើយហៅកូនរជយ ជួបជុំស៊ីក្រោយ រអឹករអាក។
រីឯតាចាស់អប្បលក្ខណ៍ ស៊ីរួចកន្ទ្រាក់ ប្រវាត្បាល់បុក។
ខោកៗគោះបោកពមផ្លុក ផ្លញៗមើលមុខ ស្រមូមដូចស្វា។
ផ្លែមៗលលែមនេត្រា ស្ងាញស្ងួបចង្កា ងងុយងោកងុក។
ងងើពភ្លើពព្លុក លលិវលុះលក់ ស្រមុកខុលៗ។
ហូរហៀរទឹកមាត់បំផុល មុខគួរខ្ពើមខ្ពល់ អាសោចអសារ។
ដេកលក់អស់ល្បត់ហើយណា ភ្ញាក់(ឡើង) ប្រវារ រកស្នូចង្រប់។
ដើរទៅសម្ដៅព្រៃសព្វ ត្រពាំងបឹងគ្រប់ ចាក់ច្រមអន្ទង់។
ហើយដាក់ជុចហើយដាក់ជុង បានមកតម្រង់ តែដេកនិងស៊ី។
ដើរដាក់ជំពាក់ទ្រព្យគេ ប្រពន្ធដៀលជេរ មិនឈឺក្បាលតា។
ងងុកសសុកតែស្រា ផឹករួចនាំគ្នា ទៅរកនេសាទ។
សព្វថ្ងៃអាស្រែពុំឃ្លាត តែងនិងពិឃាត ជីវិតសត្វផង។

ពុំមានខ្វះខាតដល់ម្តង ខុសឈ្នក់អន្ទង មិនមានទំនេរ។
ខុសបឹងត្រូវឯទន្លេ មិនឱ្យខានទេ ខានតែឱ្យបាន។
មិនស្គាល់ជាសីលជាទាន ចេះតែបំពាន់ ដោយចិត្តដោយចិត្តលោភលន់។
ជាមនុស្សឥន្ទ្រីយទុរជន មិនដែលធ្វើបុណ្យ ឱ្យទានឡើយណា។
មានតែបទ្ទិមោហា លុះដាច់អស់អា យូសនេះធ្លាក់ទៅ។
រងទុក្ខក្នុងភក់ជ្រាំជ្រៅ លំបាកក្តាត់ក្តៅ ទុលទុក្ខវេទនា។
ភ្លើងឆេះរលេះអង្គា រលួយទៅជា ខ្ទោចហើយរស់វិញ។
រស់ឡើយស្រមើងមាត់ស្ទេញ យមបាលខឹងខ្នាញ់ ចាក់ចោលនឹងស្នា។
នឹងច្បូកដូលខ្លោកកៀបករ ទើបលើងស្រែកឡូ ថាហ៏ចាក់ទៀត។
ចាក់សោតត្រូវត្រង់កណ្តៀត ស្លាប់ហើយរស់ទៀត ច្រើនគ្រាច្រើនដង។
ឥតឯល្ហែល្ហើយឡើយហោង ទល់ទុក្ខកន្លង នឹងផ្អើមពុំបាន។
ហេតុតែវេរាកម្មប្រាណ ពីជាតិមុនមាន មិនដឹងស្គាល់ត្រង់។

បាបបុណ្យសីលទានទោសគុណចិត្តជនមោហា

តែងធ្វើអំពើបាណា ហើយសេពសុរា រលាយបុណ្យបាប។
ព្រះថ្លែងសម្តែងបរមត្ថ ទុកទូន្មានសត្វ ឱ្យខំសាងសីល។
ធ្វើបុណ្យឱ្យទាន(កុំ)ខ្ជិល រើយៗ រាល់ៗ ដល់ព្រះនិព្វានហោង។

ស្មៀនឱរបានចារសត្រាដុច១ច្បាប់ឱ្យលោកស្មៀនមុច